**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៨៨. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០១៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកត្បែងមានជ័យ និងស្រុកជ័យសែន ខេត្តព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

បណ្ណាគារ ភក្តីឡ PheakdeyLaw Book Store

www.pheakdeylaw.com

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ៩.០១៥ ( ប្រាំបួនពាន់សូន្យដប់ប្រាំ ) ហិកតា ស្ថិតនៅក្នុងភូមិសាស្រ្ត ឃុំប្រមេរ ស្រុកត្បែងមានជ័យ និងឃុំតស៊ូ ស្រុកជ័យសែន ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ អាកាស្យា និងអំពៅ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៣១៦ចណលផ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ របស់សាលាខេត្តព្រះវិហារ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

បណ្ណាគារ ភក្តីឡដ៍
PheakdeyLaw Book Store

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

www.pheakdeylaw.com

## ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឡាន ហ្វេង(ខេមបូឌា) អ៊ិនវេស្ទមិនឯលីមីតធីត ខមភេនី លីមីតធីត

### ស្ថិតនៅក្នុង ឃុំប្រមេរ ស្រុកត្បែងមានជ័យ និងឃុំគស្វ ស្រុកជ័យសែន ខេត្តព្រះវិហារ




និយាមការ ព្រំប្រទលក្បាលគុក :

| Coor_x | Coor_y | N |
|---|---|---|
| 509750 | 1528091 | 1 |
| 509561 | 1526963 | 2 |
| 509235 | 1526962 | 3 |
| 509404 | 1528060 | 4 |
| 509443 | 1526344 | 5 |
| 508869 | 1525255 | 6 |
| 508334 | 1525376 | 7 |
| 508624 | 1526483 | 8 |
| 509339 | 1526635 | 9 |
| 508939 | 1525064 | 10 |
| 509183 | 1524087 | 11 |
| 508351 | 1524298 | 12 |
| 508165 | 1525259 | 13 |
| 509997 | 1527643 | 14 |
| 510092 | 1527776 | 15 |
| 510624 | 1516832 | 16 |
| 509819 | 1517187 | 17 |
| 514365 | 1514889 | 18 |
| 513903 | 1514764 | 19 |
| 513809 | 1515144 | 20 |
| 514142 | 1515167 | 21 |
| 509898 | 1526795 | 22 |
| 509964 | 1527577 | 23 |
| 510033 | 1525921 | 24 |
| 510023 | 1526740 | 25 |
| 509279 | 1524113 | 26 |
| 509192 | 1525385 | 27 |
| 509506 | 1524843 | 28 |
| 509427 | 1524188 | 29 |
| 510555 | 1523918 | 30 |
| 510555 | 1524205 | 31 |
| 510903 | 1524205 | 32 |
| 510903 | 1523918 | 33 |
| 513840 | 1523291 | 34 |
| 513840 | 1523579 | 35 |
| 514188 | 1523579 | 36 |
| 514188 | 1523291 | 37 |

**សញ្ញាសំគាល់ :**

- ព្រំប្រទលសម្បទានដីសេដ្ឋកិច្ច
- ព្រំប្រទលស្រុក
- ព្រំប្រទលឃុំ
- ផ្លូវទឹក
- ផ្លូវ
- ដីតំបន់ព្រលាន
- ព្រៃត្រូវរក្សាទុកបន្ថែមទៀត
- ព្រៃការពារប្រភពទឹក

មាត្រដ្ឋាន ១ . ១០០ ០០០

2 0 2 Km

**គំរបព្រៃឆ្នាំ២០០៦ :**

| | |
|---|---|
| ព្រៃស្រោង | ៦៨២ហ.ត |
| ព្រៃពាក់កណ្ដាលស្រោង | ២៤០ហ.ត |
| ព្រៃល្បោះ | ១០ ៦៦៣ហ.ត |
| ព្រៃកុម្មោតស្លុត | ៦៤ហ.ត |
| ដីគ្មានគំរបព្រៃ | ១៥៨ហ.ត |
| **សរុប :** | **១១ ៥៤៧ហ.ត** |

**ផ្ទៃដីស្នើសុំ: ១១ ៥៤៧ហ.ត**

**ផ្ទៃដីកាត់ចេញ :**

| | |
|---|---|
| ព្រៃត្រូវរក្សាទុកបន្ថែមទៀត | ៣៦៥ហ.ត |
| ព្រៃការពារប្រភពទឹក | ១ ១៥៧ហ.ត |
| ដីតំបន់ព្រលាន | ២០ហ.ត |
| ដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ | ១ ០០០ហ.ត |
| **ផ្ទៃដីកាត់ចេញសរុប :** | **២ ៥៤២ ហ.ត** |
| **ផ្ទៃដីផ្ដល់ជូន :** | **៩ ០០៥ ហ.ត** |

COORDINATE SYSTEM

| | |
|---|---|
| Projection | UTM |
| Zone | 48 |
| Horizontal Datum | Indian 1960 |
| Spheroid | Everest |
| UTM Grid | 2 Km |

លេខ 441/011
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ប្រមេរ ថ្ងៃទី 21 ខែ 04 ឆ្នាំ២០១១
មេឃុំ
ប្រាក់_កែន

លេខ ...../០១១
បានឃើញ និង ឯកភាព
សូមគោរពជូនលោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
គស្វ ថ្ងៃទី ... ខែ 04 ឆ្នាំ២០១១
ចាន់_ស្រី

លេខ ..................
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្ដមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ត្បែងមានជ័យ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
អភិបាលស្រុក
ឡាំង ស្មើ

លេខ ..................
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្ដមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ជ័យសែន ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
អភិបាលស្រុក
ចោម_សារឿន

លេខ ..................
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្ដមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
ប្រធានមន្ទីរកសិកម្ម
គឹម_ឡើង

លេខ 108 ដ.ខ.ស.
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្ដមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី 22 ខែ 04 ឆ្នាំ២០១១
ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី
គង់_សោភ័ណ

លេខ ..................
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និងសម្រេច
ព្រះវិហារ ថ្ងៃទី 22 ខែ 4 ឆ្នាំ២០១១
អភិបាលខេត្ត
ស៊ុំ ម៉ារ៉ា

www.pheakdeylaw.com